# កម្មនិងផលរបស់កម្ម

# មានមែនឬទេ?

*ព្រះសាសនមុនី កិម ត្រូវ ចន្ទមគ្គលោ*

*វត្តឧណ្ណាលោម ភ្នំពេញ*

*ដកស្រង់ចេញពីទស្សនាវដ្ដីពន្លឺពុទ្ធចក្រ*

*លេខ២៨ ព.ស.២៥០៥ គ.ស.១៩៦២*

***

# កម្មនិងផលរបស់កម្ម មានមែនឬទេ?

*ព្រះសាសនមុនី កិម ត្វរ ចន្ទមង្គលោ*

*វត្តឧណ្ណាលោម ភ្នំពេញ*

*ដកស្រង់ចេញពីទស្សនាវដ្តីពន្លឺពុទ្ធចក្រ*

*លេខ១៨ ព.ស.២៥០៥ គ.ស.១៩៦២*

***

*អំពើអ្វីក៏ដោយដែលគេធ្វើ ទោះបីល្អឬអាក្រក់ ហៅថា កម្ម។ ចំហាយឬកម្រៃដែលកើតលេចចេញមកអំពីនោះ ហៅថា ផលរបស់កម្ម។ ក្នុងលោកនេះមានជនពួកខ្លះដែលប្រកបដោយមោហៈ រមែងពោលបដិសេធផលរបស់កម្ម ថាផលរបស់កម្មមិនមាន, ទោះគេធ្វើល្អក្តី ធ្វើអាក្រក់ក្តី ក៏គ្មានផល, ការធ្វើនេះទុកជាមិនធ្វើដែរ។ ជនពួកនេះ មិនមែនពោលបដិសេធចំពោះតែផលរបស់កម្មប៉ុណ្ណោះទេ សូម្បីបរលោក (លោកខាងមុខ) ក៏ពោលបដិសេធថាគ្មានផងដែរ។*

*ចំណែកខាងពុទ្ធសាសនាមិនពោលបដិសេធដូច្នោះទេ គឺពោលថា ផលរបស់កម្មក៏មាន បរលោកក៏មាន។ យើងសូមលើកយករឿងមួយមកបញ្ជាក់ជាឧទាហរណ៍ ដែលមានប្រាកដក្នុងគម្ពីរខុទ្ទកនិកាយ ត្រង់មហានារទកស្សបជាតក មានសេចក្តីថា មានព្រះរាជាមួយព្រះអង្គក្នុងដែនវិទេហៈ ជាក្សត្រិយ៍ទ្រង់ព្រះនាមអង្គតិ។ ព្រះបាទអង្គតិ អង្គនេះជាស្តេចសម្បូណ៌ដោយយានវាហនៈ*

ពួកពលនិងទ្រព្យជាច្រើន។ នៅក្នុងពេលបឋមយាមនៃរាត្រីទី១៥ ជាខាងចុង នៃរដូវភ្លៀង៤ខែជារដូវរីកនៃផ្កាកុមុទ, ព្រះអង្គទ្រង់ប្រជុំអាមាត្យទាំងឡាយជា បណ្ឌិតអ្នកប្រាជ្ញ ឈ្មោះវិជយៈ១ ឈ្មោះសុនាមៈ១ ឈ្មោះអលាតៈ១ ហើយ ទ្រង់ត្រាស់សួរអាមាត្យ ទាំងនោះជាលំដាប់គ្នាថា អ្នកទាំងឡាយ ចូរពោលតាម សេចក្តីយល់ឃើញនិងសេចក្តីពេញចិត្តផ្សេងៗគ្នា ចុះថ្ងៃនេះជារាត្រីទី១៥ មាន មណ្ឌលព្រះចន្ទដ៏ស កម្ចាត់បង់នូវងងឹតគួរឲ្យរីករាយចិត្តយ៉ាងក្រៃលែង យើង ទាំងឡាយ នឹងធ្វើយ៉ាងណាទើបមានសេចក្តីសប្បាយរីករាយក្នុងរាត្រីរដូវនេះ? លំដាប់នេះសេនាបតីឈ្មោះអលាតៈ បានក្រាបបង្គំទូលមុនគេថា បពិត្រព្រះ សម្មតិទេព ព្រះអង្គមានយានវាហនៈនិងពួកពលសេនាជាច្រើនណាស់ សុទ្ធ តែជាអ្នកក្លាហានអង់អាច យើងនឹងលើកចេញទៅដើម្បីច្បាំងតតាំងនឹងព្រះ រាជាណា ដែលមិនមកចុះក្នុងអំណាច ទូលបង្គំជាខ្ញុំនឹងនាំព្រះរាជានេះមកចុះ អំណាចព្រះអង្គ នេះជាសេចក្តីយល់ផ្ទាល់ខ្លួនរបស់ទូលព្រះបង្គំជាខ្ញុំ, សូមព្រះ អង្គទ្រង់ត្រេកអរក្នុងចម្បាំងជាមួយនឹងទូលព្រះបង្គំជាខ្ញុំ។

អាមាត្យឈ្មោះសុនាមៈ បានស្តាប់ពាក្យអលាតសេនាបតីនោះហើយ ក៏ក្រាបទូលដូច្នេះថា បពិត្រមហារាជ ពួកសត្រូវទាំងអស់ មកចុះចូលក្នុង អំណាចព្រះអង្គស្រាប់ហើយតើ, ពួកសត្រូវមានគ្រឿងសស្ត្រាដាក់ចុះហើយ តែងប្រព្រឹត្តបន្ទន់បន្ទាបមករកព្រះអង្គហើយ ឯការច្បាំងចូលទូលព្រះបង្គំជាខ្ញុំ មិនពេញចិត្តទេ។ ក្នុងថ្ងៃនេះ សូមព្រះអង្គទ្រង់ក្រសាលមហោស្រព ហើយឲ្យ គេនាំយកព្រះក្រយាស្ងោយមកថ្វាយ, បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់

ត្រេកអរក្នុងការរាំច្រៀងនិងគ្រឿងប្រគំដោយកាមទាំងឡាយវិញចុះ។

អាមាត្យឈ្មោះវិជយៈ បានស្តាប់ពាក្យសុនាមៈអាមាត្យនោះហើយ ក៏ក្រាបទូលដូច្នេះថា បពិត្រមហារាជ កាមទាំងអស់តែងប្រាកដដល់ព្រះអង្គជានិច្ចហើយតើ។ កាមទាំងនេះមិនមែនព្រះអង្គបានដោយក្រទេកាលបើព្រះអង្គប្រាថ្នារីករាយដោយកាមទាំងឡាយណា កាមទាំងនោះព្រះអង្គបានសព្វៗកាលនេះមិនមែនជាសេចក្តីពេញចិត្តរបស់ទូលព្រះបង្គំជាខ្ញុំទេ។ ទូលព្រះបង្គំជាខ្ញុំយល់ឃើញថា សមណព្រាហ្មណ៍ណាជាពហុស្សូតជាអ្នកដឹងអត្ថនិងធម៌ ជាអ្នកស្វែងរកគុណ គប្បីបន្ទោបង់នូវសេចក្តីសង្ស័យនៃយើងទាំងឡាយក្នុងថ្ងៃនេះបាន យើងទាំងឡាយគួរចូលទៅរកសមណព្រាហ្មណ៍ជាពហុស្សូតនោះនេះទើបជាសេចក្តីពេញចិត្តរបស់ទូលព្រះបង្គំជាខ្ញុំ។

ព្រះរាជាព្រះនាមអង្គតិ ទ្រង់ព្រះសណ្តាប់ពាក្យនៃវិជយាមាត្យនោះហើយ ទ្រង់ត្រាស់ថា កាណ៍នេះទើបពេញចិត្តយើង ដូចពាក្យដែលវិជយាមាត្យនេះពោល។ បើដូច្នេះយើងគួរចូលទៅរកបណ្ឌិតណា ដែលជាអ្នកដឹងអត្ថនិងធម៌ ជាអ្នកស្វែងរកគុណអាចបន្ទោបង់នូវសេចក្តីសង្ស័យនៃពួកយើងក្នុងថ្ងៃនេះបាន។ អលាតសេនាបតី បានស្តាប់ព្រះបន្ទូលនៃព្រះបាទវិទេហៈហើយ ក៏ក្រាបទូលថា បពិត្រមហារាជ មានអចេលក៏មួយព្រះអង្គ ដែលគេសន្មតថាជាអ្នកប្រាជ្ញ គង់នៅក្នុងមិគទាយវ័ន។ អចេលក៏នោះឈ្មោះ គុណៈជាកស្សបគោត្រ ជាអ្នកចេះដឹង ជាអ្នកពោលពាក្យដ៏វិចិត្រ ជាគណាចារ្យ, បពិត្រព្រះសម្មតិទេព យើងគួរចូលទៅរកអចេលក៏នោះ លោកអាចនឹង

បន្ទាបង់នូវសេចក្ដីសង្ស័យនៃពួកយើងបាន។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យនៃអលាតសេនាបតីហើយ ទ្រង់ត្រាស់បង្គាប់នាយសារថីថា យើងនឹងទៅកាន់មិគទាយវ័ន អ្នកចូរនាំយកនូវយានដែលទឹមហើយមកក្នុងទីនេះ។ នាយសារថីលុះទទួលព្រះរាជបញ្ជាហើយ ក៏ចាត់ចែងទឹមរាជរថនាំមកថ្វាយព្រះរាជាៗ ទ្រង់ស្ដេចយាងទៅដោយរាជរថដ៏ល្អវិចិត្រនោះ ជាមួយនឹងពួកអាមាត្យ មានទាំងសេនារេហ៍ពលជាច្រើនតាមដង្ហែព្រះអង្គទៅផង។ ព្រះបាទវិទេហៈ ទ្រង់ស្ដេចយាងទៅកាន់មិគទាយវ័ន លុះដល់ហើយ ទ្រង់ចុះពីរាជរថ យាងផ្ទាល់ព្រះបាទជាមួយនឹងពួកអាមាត្យ ចូលទៅរកអាជីវកឈ្មោះ គុណៈ។ គ្រានោះពួកព្រាហ្មណ៍និងគហបតីណា ដែលមកប្រជុំមុនក្នុងឧទ្យាននោះ ព្រះរាជាក៏មិនបណ្ដេញព្រាហ្មណ៍និងគហបតីទាំងនោះ ដែលមកកាន់ទីដោយមិនបានធ្វើឱកាសឡើយ។ លំដាប់នោះព្រះរាជា ទ្រង់យាងចូលទៅគង់ប្រថាប់លើរាជាសនៈក្នុងទីដ៏សមគួរហើយ ទើបទ្រង់ត្រាស់នូវពាក្យដែលគួររីករាយនិងពាក្យដែលមិនគួររឭកជាមួយអចេលក៍នោះថា បពិត្រលោកដ៏ចម្រើន សរីរៈរបស់លោកអាចប្រព្រឹត្តទៅបានទេឬ? សុខភាពរបស់លោកប្រព្រឹត្តទៅស្រួល មិនមានជំងឺតម្កាត់ទេឬ? ការចិញ្ចឹមជីវិតរបស់លោកមិនលំបាកទេឬ? ចក្ខុរបស់លោកមិនងងឹតស្រវាំងទេឬ? អចេលក៍ឈ្មោះ គុណៈ បានសម្ដែងអាការរីករាយតបនឹងព្រះបាទវិទេហៈវិញដោយពាក្យថា បពិត្រមហារាជ ព្រះអង្គទ្រង់ត្រាស់សួរអាត្មាភាពចំពោះហេតុការណ៍ណា ហេតុការណ៍នោះអាត្មាភាពបានសុខស្រួលបួលទាំងអស់ ឥតមានអ្វីជាការលំបាកឡើយ, បពិត្រមហារាជ

បច្ចន្តគ្រាមទាំងឡាយរបស់ព្រះអង្គបានសុខសន្តិភាព មិនមានការបះបោរទេឬ? រាជរថរបស់ព្រះអង្គដែលទ្រង់ព្រះរាជដំណើរមក មិនមានការខូចខាតទេឬ? ព្យាធិទាំងឡាយមិនដុតកម្ដៅសរីរៈរបស់ព្រះអង្គទេឬ? លំដាប់នេះព្រះបាទវិទេហៈ ដែលមានព្រះរាជហឫទ័យទ្រង់ប្រាថ្នាធម៌ ក៏រីករាយតប ទើបទ្រង់ប្រារព្ធសួរអត្ថជង ធម៌ផងនិងហេតុដែលគួរដឹងផងថា បពិត្រកស្សបគោត្រ សត្វគប្បីប្រព្រឹត្តធម៌ចំពោះមាតាបិតាដូចម្ដេច? គប្បីប្រព្រឹត្តចំពោះអាចារ្យដូចម្ដេច? គប្បីប្រព្រឹត្តចំពោះកូននិងប្រពន្ធដូចម្ដេច? គប្បីប្រព្រឹត្តចំពោះមនុស្សចាស់ព្រឹទ្ធាចារ្យដូចម្ដេច? ចំពោះសមណព្រាហ្មណ៍ដូចម្ដេច? ចំពោះពួកពលដូចម្ដេច? មួយទៀត សត្វទាំងឡាយប្រព្រឹត្តធម៌ដូចម្ដេចដែលលះលោកនេះហើយទៅកាន់សុគតិ? សត្វពួកណាដែលឋិតនៅក្នុងអធម៌ដូចម្ដេចមានក្បាលសំយុងចុះធ្លាក់ទៅកាន់នរក? អចេលក៍ឈ្មោះ គុណៈ បានស្ដាប់ព្រះបន្ទូលព្រះបាទវិទេហៈហើយ ក៏ឆ្លើយទូលដូច្នេះថា បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់នូវបទដែលពិតមិនឃ្លៀងឃ្លាតរបស់អាត្មាភាពនេះចុះៈ

បពិត្រព្រះសម្មតិទេព ផលល្អនិងផលអាក្រក់របស់បុគ្គលអ្នកប្រព្រឹត្តធម៌មិនមានទេ, បរលោកក៏មិនមានដែរ ព្រោះថាក្នុងលោកនេះ មាននរណាមកពីបរលោក។ មួយទៀតមាតាបិតាមិនមានទេ, អាចារ្យមិនមានទេ, អ្នកណានឹងទូន្មាននូវបុគ្គលដែលមិនទាន់ទូន្មានបាន, សត្វទាំងឡាយមានតុល្យភាពស្មើៗគ្នា, សត្វទាំងឡាយទៀងដូចជាទូកតូចចងភ្ជាប់នឹងទូកធំ, សត្វតែងបាននូវរបស់ដែលត្រូវបានឯងៗ ផលទានក្នុងបរលោកនឹងមានមកពីណា។ បពិត្រ

ព្រះសម្មតិទេព ផលទានមិនមានទេ, សេចក្តីព្យាយាមមិនមានអំណាចទេ, ទាន គឺពួកជនពាលទេតើ ដែលបញ្ញត្តទុកមក ឯពួកបណ្ឌិតចាំតែទទួលយកនូវទាន នោះពួកជនពាលជាអ្នកមិនមានអំណាច សម្គាល់ខ្លួនថាជាបណ្ឌិត រមែងឲ្យ ទានដល់បណ្ឌិតទាំងឡាយ។ ដី ទឹក ភ្លើង ខ្យល់ សុខ ទុក្ខនិងជីវិត ទាំង៧ នេះ ទើបឈ្មោះថាជារបស់ទៀងជាសភាវៈឲ្យដាច់មិនបានឲ្យកម្រើកមិនបាន។ ពួកទៀងទាំង៧នេះ គប្បីរស់ជាដរាប បើទោះជាបុគ្គលកាត់ហើយ មិនឈ្មោះ ថាកាត់ បុគ្គលអ្នកសម្លាប់ក្តី អ្នកកាត់ក្តី ក៏មិនមាន អ្នកណាសម្លាប់មានឈ្មោះ ថាមិនសម្លាប់ ឯគ្រឿងសស្ត្រាទាំងឡាយ គ្រាន់តែចូលទៅក្នុងចន្លោះនៃពួក ទាំងនោះប៉ុណ្ណោះ បុគ្គលណាយកដាវទៅកាត់ក្បាលជនដទៃ បុគ្គលនោះមិន មានឈ្មោះថាកាត់ពួកទៀងទាំងនោះទេ ផលនៃបាបក្នុងអំពើនោះនឹងមានមក ពីណា, សត្វទាំងអស់ លុះតែអន្ទោលទៅអស់មហាកប្ប៨៤ ទើបបរិសុទ្ធឯង កាលបើមិនទាន់ដល់កាលកំណត់នោះទេ ពួកសត្វសូម្បីប្រព្រឹត្តល្អច្រើនក៏មិន បរិសុទ្ធ ធ្វើបាបច្រើនក៏មិនកន្លងហួសនូវខណៈនោះដែរ សេចក្តីបរិសុទ្ធរបស់ យើងទៅតាមលំដាប់នៃកប្ប៨៤ មិនកន្លងហួសកម្រិតដ៏ទៀងនោះបានទេ ដូច សាគរមិនកន្លងហួសច្រាំងទៅបានឡើយ។

អលាតសេនាបតីលុះបានស្តាប់ពាក្យអធិប្បាយនៃអចេលកៈនោះហើយ ក៏ពោលដូច្នេះថា លោកម្ចាស់ពោលពាក្យណា ពាក្យនោះជាទីពេញចិត្តខ្ញុំ ណាស់ ព្រោះខ្ញុំបានរឭកឃើញជាតិរបស់ខ្លួនពីក្នុងកាលមុន ដែលអន្ទោល ទៅហើយថា កាលនោះខ្ញុំបានកើតជាមនុស្សឈ្មោះបង្គិលៈជាអ្នកប្រព្រឹត្ត

អាក្រក់ តែងសម្លាប់សត្វជាច្រើនមាន គោ ក្របី ជ្រូក ពពែជាដើម នៅក្នុងក្រុងពារាណសី។ លុះខ្ញុំច្យុតចាកអត្តភាពនោះហើយក៏បានមកកើតក្នុងត្រកូលនេះ បានឋានៈជាសេនាបតីក៏ស្តុកស្តម្ភជងទៀត ផលបាបរបស់ខ្ញុំមិនមានពិតបានជាខ្ញុំមិនទៅនរក។ គ្រានោះ មានបុរសកម្សត់ម្នាក់ជាទាសៈឈ្មោះ វីជកៈ រក្សាឧបោសថសីលហើយ ចូលទៅកាន់សម្នាក់នៃអចេលក៍ឈ្មោះគុណៈក្នុងពេលនោះដែរ។ វីជកៈនោះ លុះបានស្តាប់ពាក្យរបស់គុណៈនិងពាក្យរបស់អលាតសេនាបតីដែលបានពោលហើយ ដ៏ដកដង្ហើមធំ យំបង្ហូរទឹកភ្នែក។ ព្រះបាទវិទេហៈ ទ្រង់ត្រាស់សួរវីជកៈនោះថា នៃអ្នក, ហេតុអ្វីបានជាអ្នកយំ, អ្នកយំដើម្បីអ្វី, អ្នកបានឮឬបានឃើញអ្វីឬក៏អ្នកដល់នូវទុក្ខវេទនាដូចម្តេច ចូរប្រាប់យើងឲ្យដឹងផង។ វីជកៈបានក្រាបបង្គំទូលថា បពិត្រមហារាជ ទុក្ខវេទនារបស់ទូលព្រះបង្គំជាខ្ញុំមិនមានទេ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ចុះ, ទូលព្រះបង្គំជាខ្ញុំរឭកឃើញនូវសេចក្តីសុខរបស់ទូលព្រះបង្គំជាខ្ញុំ ក្នុងជាតិពីមុនកាលដែលបានកើតជាភាវសេដ្ឋី ជាអ្នកត្រេកអរក្នុងគុណធម៌ ក្នុងបុរីឈ្មោះសាកេត។ មានពួកព្រាហ្មណ៍និងគហបតីជាច្រើនតែងពោលសរសើរទូលបង្គំជាខ្ញុំថា ជាអ្នកត្រេកអរក្នុងការចែករំលែកទានជាអ្នកប្រព្រឹត្តសុចរិតត្រឹមត្រូវ ទូលព្រះបង្គំជាខ្ញុំមិនដែលហ៊ាននឹកនានូវអំពើអាក្រក់ណាមួយដែលខ្លួនធ្វើហើយទេ។ លុះទូលព្រះបង្គំជាខ្ញុំ ច្យុតចាកអត្តភាពនោះ ក៏ត្រឡប់មកកើតក្នុងគភ៌នៃកុម្ភទាសីជាស្រីទុគ៌តក្នុងក្រុងមិថិលានេះ, តាំងពីកើតមក ទូលព្រះបង្គំជាខ្ញុំ ទុគ៌តក្រៃពេក, សូម្បីទូលព្រះបង្គំជាខ្ញុំទុគ៌តម្លឹងហើយ ក៏នៅតែតាំងចិត្តប្រព្រឹត្តល្អ តែង

ឲ្យភត្តពាក់កណ្ដាលដល់បុគ្គលអ្នកត្រូវការ, តែងរក្សាឧបោសថអស់ថ្ងៃទី១៤ និងថ្ងៃទី១៥សព្វៗកាលទៀត អំពើដែលសន្សំល្អទាំងអស់នេះ ជារបស់ឥតផលដោយពិត ទូលព្រះបង្គំជាខ្ញុំសម្គាល់ថា ទានក្ដី សីលក្ដី ទាំងអស់នេះ មិនមានប្រយោជន៍ទេ ដូចជាអលាតសេនាបតីពោលដែរ អំពើដែលទូលព្រះបង្គំជាខ្ញុំទទួលទុក្ខទោសដោយជាក់ស្ដែងនេះ ប្រៀបដូចអ្នកលេងមិនមានសិល្បៈ ឬដូចអលាតសេនាបតីលេងបាស្កាបានរៀនស្ទាត់ហើយ ក៏បានទទួលនូវការឈ្នះ។ ទូលព្រះបង្គំជាខ្ញុំមិនឃើញទ្វារសម្រាប់ទៅកាន់សុគតិសោះ ព្រោះហេតុនោះ បានជាទូលព្រះបង្គំជាខ្ញុំយំទួញ ព្រោះបានស្ដាប់ភាសិតនៃអចេលកៈជាកស្សបគោត្រ។

ព្រះបាទវិទេហៈ ទ្រង់ព្រះសណ្ដាប់ពាក្យវីជកៈ ហើយទ្រង់ត្រាស់ថា ម្នាលវីជកៈទ្វារនៃសុគតិមិនមានទេ អ្នកចូរសង្ឃឹមការដ៏ទៀងចុះ ព្រោះថាសុខនិងទុក្ខជារបស់ទៀង ដែលពួកសត្វរមែងតែបានសេចក្ដីបរិសុទ្ធិ ព្រោះសង្សាររបស់សត្វទាំងអស់រមែងមាន ព្រោះហេតុនោះ អ្នកកុំប្រញាប់ចង់ឃើញក្នុងកាលដែលមិនទាន់ដល់កំណត់នោះឡើយ, ពីដើមមកយើងជាមនុស្សល្អ បានខ្វល់ខ្វាយបម្រើនូវពួកព្រាហ្មណ៍និងគហបតីដោយការប្រៀនប្រដៅ ក៏នាំឲ្យយើងសាបសូន្យចាកសេចក្ដីត្រេកអរក្នុងកាមគុណជាលំដាប់។ លំដាប់នោះ ព្រះរាជា ទ្រង់ត្រាស់នឹងអចេលក៍ឈ្មោះគុណៈថា បពិត្រលោកដ៏ចម្រើន ភាសិតរបស់លោកជាទីពេញចិត្តខ្ញុំហើយ, ប្រសិនបើមានការប្រជុំ យើងនឹងជួបគ្នាម្ដងទៀត លុះមានព្រះតម្រាស់ដូចនេះហើយ ក៏ទ្រង់យាងត្រឡប់ទៅ

កាន់ព្រះរាជនិវេសន៍របស់ព្រះអង្គវិញ។ កាលបើរាត្រីនោះកន្លងទៅហើយ ព្រះបាទអង្គតិ ទ្រង់ប្រជុំពួកអាមាត្យក្នុងព្រះរាជដំណាក់ ហើយត្រាស់ថា អាមាត្យទាំងឡាយ ចូរចាត់ចែងកាមទាំងឡាយ ក្នុងវិមានច័ន្ទក៍របស់យើងសព្វៗកាល លុះទ្រង់ត្រាស់តម្រាស់នេះហើយ ក៏សម្គាល់នូវកាមទាំងឡាយដ៏ច្រើន ហើយឈប់ខ្វល់ខ្វាយចំពោះព្រាហ្មណ៍គហបតីនិងករណីយកិច្ចណានីមួយ។

តាំងពីកាលនោះមករហូតដល់រាត្រីទី១៤ គ្រានោះព្រះរាជកញ្ញារបស់ព្រះបាទវិទេហៈ ព្រះនាមរុចា ជាធីតាបង្កើត បានពោលចំពោះស្ត្រីព្រះស្នំជាបរិវារទាំងឡាយថា ថ្ងៃនេះចូរនាងប្រដាប់ស្អិតស្អាងកាយគ្រប់ៗគ្នា, ព្រោះថ្ងៃស្អែកជាថ្ងៃទី១៥ ជាថ្ងៃទិព្វ យើងនឹងទៅកាន់សម្នាក់ព្រះបិតា។ ឯព្រះនាងរុចានោះ បានស្អិតស្អាងកាយដោយគ្រឿងអាករណៈទាំងពួង ឋិតនៅក្នុងកណ្តាលនៃពួកស្ត្រីជាបរិវារ បានចូលទៅកាន់វិមានចន្ទក៍ដោយសិរីសម្បត្តិដ៏ល្អរុងរឿង លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះបាទវិទេហៈជាព្រះបិតា ហើយឋិតនៅក្នុងទីដ៏សមគួរ។ ព្រះបាទវិទេហៈ ទ្រង់ទតឃើញការប្រជុំនោះដូចជាទីប្រជុំនៃពួកស្ត្រីទេពអប្សរ ទើបមានព្រះតម្រាស់ទៅកាន់នាងរុចាជាធីតាថា ម្នាលនាងរុចាជាកូនស្រីសម្លាញ់ឪពុក នាងត្រេកអរក្នុងប្រាសាទនិងស្រះបោក្ខរណីខាងក្នុងដែរឬពួកជនបាននាំយកភោជនផ្សេងៗ មកថ្វាយនាងដែរឬមួយទៀត នាងខ្វះខាតដោយវត្ថុអ្វី ជនទាំងឡាយបាននាំយកវត្ថុមកថ្វាយនាងដែរឬ នាងចូរធ្វើតាមសេចក្ដីសប្បាយចិត្តចុះ សូម្បីរបស់ស្មើដោយព្រះចន្ទ ក៏ឪពុកផ្តល់ឲ្យនាងបានដែរ។ នាងរុចាទេវី បានស្តាប់ព្រះរាជឱង្ការព្រះបិតាហើយ ទើបទូល

គបថា បពិត្រព្រះបិតា របស់ទាំងអស់នោះ ខ្ញុំម្ចាស់តែងបានក្នុងសម្នាក់ព្រះអង្គ សព្វកាល ឥតមានការលំបាកអ្វីឡើយ។ ស្អែកជាថ្ងៃទី១៤ ជាថ្ងៃទិព្វ សូមព្រះអង្គទ្រង់ព្រះរាជទានកហាបណៈមួយពាន់ដល់ខ្ញុំម្ចាស់ៗ នឹងឲ្យទានដល់ពួកស្មូមយាចកអ្នកកម្សត់ទុគិតទូទៅ តាមទំនងដែលខ្ញុំម្ចាស់ធ្លាប់ឲ្យមកហើយ។

ព្រះរាជាអង្គតិ លុះទ្រង់ព្រះសណ្ដាប់នាងរុចាហើយ ក៏ទ្រង់ត្រាស់ថា ទ្រព្យសម្បត្តិដ៏ច្រើនឈ្មោះថានាងធ្វើឲ្យវិនាស ធ្វើឲ្យឥតប្រយោជន៍ ធ្វើឲ្យឥតផលហើយ, នាងរក្សាឧបោសថតមមិនបរិភោគបាយទឹកជានិច្ច បុណ្យមិនមានដល់បុគ្គលដែលមិនបរិភោគទេ, នាងឃើញទេ ដូចយ៉ាងទាសៈឈ្មោះវីជកៈបានស្ដាប់ភាសិតរបស់លោកគ្រូអចេលក៍ឈ្មោះគុណៈ លុះស្ដាប់បានហើយក៏ដកដង្ហើមធំយំសម្រក់ទឹកភ្នែក ដោយនឹកស្ដាយចំពោះអំពើល្អ ដែលខ្លួនខំធ្វើហើយត្រឡប់ទៅជាឥតប្រយោជន៍។ ម្នាលនាងរុចា កាលបើនាងមានជីវិតរស់នៅដរាបណា នាងកុំអត់បាយឡើយ, បុណ្យកុសលអ្វីគ្មានទេ ទាំងបរលោកក៏គ្មានដែរ, ព្រោះហេតុអ្វីនាងខំប្រឹងធ្វើខ្លួនឲ្យលំបាកឥតប្រយោជន៍, ឪពុកបានស្ដាប់ភាសិតរបស់លោកគ្រូអចេលក៍ឈ្មោះគុណៈ លោកបានសម្ដែងប្រាប់ឪពុកដោយសព្វគ្រប់អស់ហើយ, ឪពុកបានសន្និដ្ឋានច្បាស់ហើយថា កម្មនិងផលរបស់កម្មមិនមានទេ។

នាងរុចា ជាស្ត្រីមានប្រាជ្ញាស្គាល់ហេតុផល កាលបើបានស្ដាប់ព្រះបន្ទូលនៃព្រះបាទវិទេហៈជាព្រះបិតាហើយ ទើបពោលពាក្យនេះនឹងព្រះបិតាថា ពីដើមខ្ញុំម្ចាស់គ្រាន់តែឮគេថា ឥឡូវរឿងនេះខ្ញុំម្ចាស់បានឃើញជាក់ច្បាស់

ហើយថា បុគ្គលណាសេពគប់នឹងជនពាល បុគ្គលនោះរមែងក្លាយទៅជាជនពាលដែរ។ ដ្បិតថា បុគ្គលវង្វេងទៅអាស្រ័យនឹងបុគ្គលវង្វេង រមែងដល់នូវសេចក្តីវង្វេងដ៏ក្រៃលែង ដូចអលាតសេនាបតីនិងទាសៈឈ្មោះវីជកៈ គួរវង្វេងទៅចុះ តែព្រះអង្គកុំវង្វេងដូច្នេះឡើយ។ បពិត្រព្រះសម្មតិទេព ព្រះអង្គមានប្រាជ្ញាជាអ្នកប្រាជ្ញឈ្លាសក្នុងសេចក្តីចម្រើននិងសេចក្តីវិនាស ហេតុអ្វីព្រះអង្គទៅជាប្រហែសនឹងពួកជនពាលហើយលុះក្នុងទិដ្ឋិដ៏ថោកទាបទៅវិញ។ ប្រសិនបើ សត្វរមែងបរិសុទ្ធដោយគន្លងនៃសង្សារដូចពាក្យអចេលកឈ្មោះគុណៈពោលមែន បព្វជ្ជា (ការបួស) របស់អចេលកឈ្មោះគុណៈនោះ ក៏គ្មានប្រយោជន៍អ្វីដែរ, អចេលកឈ្មោះគុណៈជាមនុស្សវង្វេងដោយមោហៈដល់នូវភាពជាអ្នកអាក្រាត ដូចជាសត្វកណ្តូបទម្លាក់ខ្លួនចុះទៅក្នុងគំនរភ្លើងកំពុងឆេះ។ ជនមានចំនួនជាច្រើននាក់ ដែលជាមនុស្សល្ងង់ខ្លៅ ត្រូវអចេលកឈ្មោះគុណៈទូន្មានហើយថា សេចក្តីបរិសុទ្ធិព្រោះសង្សារ ក៏ជឿតាមហើយបដិសេធកម្មផលចោល ប្រយោជន៍ដែលបុគ្គលកាន់យកមិនល្អពីក្នុងកាលមុន ក៏រមែងក្លាយទៅជាទោសដូចត្រីដែលនឹងរួចអំពីសន្ទូចបានដោយក្រ។ បពិត្រមហារាជ ខ្ញុំម្ចាស់សូមធ្វើសេចក្តីឧបមាថ្វាយព្រះអង្គ ប្រៀបដូចទូករបស់ពួកឈ្មួញដែលផ្ទុកភារៈដ៏ធ្ងន់ហួសប្រមាណនាំទៅនូវភារៈដ៏ធ្ងន់លើសលប់ រមែងលិចចុះក្នុងនរកក៏យ៉ាងនោះដែរ។ បពិត្រព្រះសម្មតិទេព ភារៈដ៏ធ្ងន់របស់អលាតសេនាបតីមិនទាន់ពេញប្រៀបនៅឡើយទេ អលាតសេនាបតីទៅកាន់ទុគ្គតិព្រោះបាបណា គាត់នៅតែសន្សំបាបនោះ។ អលាតសេនាបតី ដែលបាន

ទទួលនូវសេចក្តីសុខចម្រើន ក៏ដោយសារអានិសង្សបុណ្យដទៃដែលគាត់បានធ្វើពីក្នុងកាលមុននោះឯង។ ឥឡូវបុណ្យនោះរបស់គាត់អស់ហើយ បានជាគាត់ត្រេកអរក្នុងអកុសលកម្ម លះបង់នូវផ្លូវត្រង់ហើយដើរទៅតាមផ្លូវវៀចវិញ ប្រៀបដូចវត្ថុធ្ងន់ ដែលគេដាក់ក្នុងមណ្ឌលនៃជញ្ជីង ដងជញ្ជីងក៏បះឡើង កាលបើភារៈធ្ងន់នោះគេដាក់ចេញហើយ ក្បាលជញ្ជីងក៏ងើបឡើង យ៉ាងណាមិញ នរជនកាលសន្សំបុណ្យសូម្បីបន្តិចម្តងៗ ដូចជាទាសៈឈ្មោះវីជកៈ កាលប្រាថ្នាសុគតិ រមែងត្រេកអរក្នុងកុសលកម្មដែលមានផលល្អក៏យ៉ាងនោះដែរ។ វីជកៈបានឃើញទុក្ខណាចំពោះខ្លួនក្នុងថ្ងៃនេះ ពីព្រោះតែបាបដែលគាត់បានធ្វើទុកពីក្នុងកាលមុន ទើបគាត់បានទទួលនូវទុក្ខនោះ, បាបរបស់គាត់នោះអស់ បានជាគាត់ត្រេកអរក្នុងកុសលកម្ម ព្រោះហេតុនេះសូមព្រះអង្គកុំគប់រកអចេលក៏ឈ្មោះគុណៈ ហើយមកកាន់ផ្លូវខុសឡើយ។ បពិត្រព្រះរាជា បុគ្គលគប់រកនូវបុគ្គលណាៗ ជាសប្បុរសឬអសប្បុរស មានសីលឬមិនមានសីល រមែងលុះនូវអំណាចនៃបុគ្គលនោះៗឯង ប្រៀបដូចបុគ្គលខ្ចប់ត្រីស្អុយដោយស្លឹកឈើណា ស្លឹកឈើនោះទៅជាមានក្លិនស្អុយផ្សាយទៅ ខ្ចប់ក្រស្នាមានក្លិនក្រអូបដោយស្លឹកឈើណា ស្លឹកឈើនោះទៅជាមានក្លិនក្រអូបផ្សាយទៅយ៉ាងមិញ ការសេពគប់នូវបុគ្គលពាលនិងបុគ្គលជាអ្នកប្រាជ្ញ ក៏យ៉ាងនោះដែរ ព្រោះហេតុនេះ បណ្ឌិតអ្នកមានប្រាជ្ញ កាលបើដឹងច្បាស់នូវភាពនៃខ្លួនដែលប្រែប្រួលបានដូចជាកញ្ចប់នៃស្លឹកឈើ មិនត្រូវសេពគប់នឹងអសប្បុរសទេ ត្រូវតែសេពគប់នឹងសប្បុរស ព្រោះថាពួកអសប្បុរស តែងនាំទៅកាន់ទុគ្គតិ

ពួកសប្បុរសតែងនាំទៅកាន់សុគតិ។

បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់បានរឭកឃើញនូវកំណើតនៃខ្លួន ដែលអន្ទោលទៅមកក្នុងភព អស់៧ជាតិមកហើយនិង៧ជាតិទៀត ដែលខ្ញុំម្ចាស់នឹងច្យុតចាកអត្តភាពនេះទៅក្នុងអនាគត។ ក្នុងកាលពីមុន ជាតិណារបស់ខ្ញុំម្ចាស់ជាគម្រប់៧, ក្នុងជាតិនោះ ខ្ញុំម្ចាស់បានកើតជាកូនជាងមាសភេទជាប្រុសក្នុងរាជគហបុរី ដែនមគធៈ។ បាបដ៏ច្រើនខ្ញុំម្ចាស់បានធ្វើហើយ ព្រោះអាស្រ័យនឹងសម្លាញ់ម្នាក់ជាមនុស្សលាមក ខ្ញុំម្ចាស់ទាំងពីរនាក់ តែងបៀតបៀននូវប្រពន្ធនៃជនដទៃ ប្រព្រឹត្តធ្វើខ្លួនហាក់ដូចជាមិនចេះស្លាប់។ អំពើបាបនោះកប់នៅដូចរងើកភ្លើងដែលកប់នៅក្នុងផេះ, តពីជាតិនោះទៅ ខ្ញុំម្ចាស់បានទៅកើតក្នុងត្រកូលសេដ្ឋីក្នុងវំសភូមិ ក្រុងកោសម្ពី ជាកូនប្រុសតែមួយ ជាត្រកូលស្តុកស្តម្ភមានទ្រព្យសម្បត្តិច្រើនដោយកុសលកម្មដទៃ, ក្នុងកាលនោះខ្ញុំម្ចាស់បានសេពគប់នឹងមិត្រសម្លាញ់ម្នាក់ អ្នកត្រេកអរក្នុងកុសលជាបណ្ឌិតបរិបូណ៌ដោយការចេះដឹង មិត្រសម្លាញ់នោះបានដឹកនាំខ្ញុំម្ចាស់ឲ្យតម្កល់នៅក្នុងអំពើជាប្រយោជន៍, ខ្ញុំម្ចាស់បានរក្សាឧបោសថអស់រាត្រីទី១៤និងទី១៥ដ៏ច្រើន កុសលកម្មដែលខ្ញុំម្ចាស់ធ្វើនោះនៅកប់ដូចជាកំណប់ក្នុងទឹក។ បណ្តាបាកម្មទាំងឡាយ បរទារកកម្មណា ដែលខ្ញុំម្ចាស់បានធ្វើហើយក្នុងកាលដែលកើតជាកូនជាងមាសក្នុងដែនមគធៈ ផលនៃបរទារកកម្មនោះផ្តល់ឲ្យក្នុងកាលជាខាងក្រោយ ដូចបុគ្គលអ្នកបរិភោគភោជនដែលលាយដោយពិសដ៏កាចដូច្នេះ។ បពិត្រព្រះរាជា ខ្ញុំម្ចាស់លុះច្យុតចាកត្រកូលសេដ្ឋីនោះមក ទៅឆេះនៅក្នុងរោរុវនរក

អស់កាលដ៏យូរដោយបាបកម្មរបស់ខ្លួនពីមុននោះ ខ្ញុំម្ចាស់កាលរឭកឃើញសេចក្តីទុក្ខក្នុងនរកនោះ រមែងមិនបានសេចក្តីសុខសោះ, ខ្ញុំម្ចាស់រងសេចក្តីទុក្ខនៅក្នុងរោរុពនរកនោះអស់ឆ្នាំដ៏ច្រើន លុះរួចហើយក៏បានមកកើតជាសត្វពពែ ត្រូវគេក្រៀវអណ្តៈក្នុងក្រុងភិន្នាគត។ ខ្ញុំម្ចាស់បាននាំពួកកូននៃអាមាត្យដោយខ្នងផង គេទឹមដោយរថផង នេះជាផលកម្ម គឺការគប់រកនូវប្រពន្ធនៃបុគ្គលដទៃរបស់ខ្ញុំម្ចាស់នោះ។ បពិត្រព្រះរាជា ខ្ញុំម្ចាស់លុះច្យុតចាកអត្តភាពនៃពពែនោះហើយ ក៏ទៅកើតជាស្វាក្នុងព្រៃធំ ត្រូវស្វាជាមេហ្វូងជាសត្វកាចខាំកាត់ពូជខ្ញុំម្ចាស់ចេញ នេះជាផលកម្ម គឺការគប់រកនូវប្រពន្ធនៃបុគ្គលដទៃរបស់ខ្ញុំម្ចាស់នោះ។ បពិត្រព្រះរាជា ខ្ញុំម្ចាស់លុះច្យុតចាកអត្តភាពនៃស្វានោះហើយ ក៏ទៅកើតជាគោក្នុងដែនទសន្នៈ ជាគោបម្រើមានសន្ទុះលឿន ត្រូវគេក្រៀវ, ខ្ញុំម្ចាស់បានអូសរទេះអស់កាលដ៏យូរ នេះជាផលកម្ម គឺការគប់រកនូវប្រពន្ធនៃបុគ្គលដទៃរបស់ខ្ញុំម្ចាស់នោះ។ បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់ច្យុតចាកអត្តភាពនៃគោនោះហើយបានមកកើតក្នុងត្រកូលមួយក្នុងដែនវជ្ជី ដោយភេទជាមនុស្សខ្ទើយ គឺមិនមែនស្រី មិនមែនប្រុស នេះជាផលកម្ម គឺការគប់ប្រពន្ធនៃបុគ្គលដទៃរបស់ខ្ញុំម្ចាស់។ បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់ច្យុតចាកអត្តភាពខ្ទើយនោះហើយ បានទៅកើតជាស្រីទេពអប្សរក្នុងឋានតាវត្តិង្សទេវលោកជាស្ត្រីបម្រើនៃទេវរាជឈ្មោះសក្កៈ។ បពិត្រព្រះរាជា ខ្ញុំម្ចាស់ឋិតនៅក្នុងឋានតាវត្តិង្សនោះ បានរឭកឃើញជាតិ៧ទៀត ដែលខ្ញុំម្ចាស់នឹងទៅក្នុងអនាគត។ កុសលណាដែលខ្ញុំម្ចាស់កើតជាកូនសេដ្ឋីក្នុងក្រុងកោសម្ពី កុសល

នោះតាមមកឲ្យផល ខ្ញុំម្ចាស់ច្យុតចាកអត្តភាពជាទេពធីតានោះហើយ នឹងអន្ទោលទៅក្នុងទេវលោកនិងមនុស្សលោក។ បពិត្រមហារាជ ខ្ញុំម្ចាស់ដែលមានគេធ្វើសក្ការបូជាជានិច្ចអស់៧ជាតិ តែខ្ញុំម្ចាស់នៅតែមិនរួចចាកភេទជាស្រីអស់គតិ៦នេះ លុះដល់គតិជាគម្រប់៧ ខ្ញុំម្ចាស់នឹងកើតជាទេវបុត្រភេទប្រុស មានឫទ្ធិច្រើនដ៏ឧត្តមក្នុងពួកទេវតា។

បពិត្រមហារាជ សូមព្រះអង្គទ្រង់ជ្រាបថា កម្មទាំងឡាយរមែងអន្ទោលតាមអស់ជាតិជាអសង្ខេយ្យដូច្នេះឯង ព្រោះថា កម្មល្អក្តី កម្មអាក្រក់ក្តី ដែលបុគ្គលធ្វើហើយ មិនវិនាសសាបសូន្យទេ។ បុគ្គលណា ចង់បានភោគៈជាទិព្វអាយុ យសនិងសុខជាទិព្វ ត្រូវវៀរបង់នូវអំពើបាបទាំងឡាយ ហើយប្រព្រឹត្តសុចរិតធម៌៣យ៉ាង។ បុរសឬស្ត្រី ជាអ្នកមិនធ្វេសប្រហែសក្នុងអំពើអាក្រក់ដោយកាយវាចាចិត្ត មានប្រាជ្ញាជាគ្រឿងពិចារណា ឈ្មោះថាកើតមកដើម្បីប្រយោជន៍របស់ខ្លួន។ ពួកមនុស្សណាមួយ ក្នុងជីវលោក ជាអ្នកមានយសនិងភោគៈបរិបូណ៌ទាំងអស់ ពួកមនុស្សទាំងនោះ ឈ្មោះថាគេបានសន្សំកម្មល្អហើយពីក្នុងកាលមុនដោយឥតសង្ស័យឡើយ ព្រោះថាសត្វទាំងអស់ សុទ្ធតែមានកម្មល្អនិងអាក្រក់ជារបស់ខ្លួន បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ព្រះតម្រិះរឿយៗ ដោយព្រះអង្គឯងចុះ។ ព្រះរាជកញ្ញាព្រះនាមរុចា បានញ៉ាំងព្រះបាទអង្គតិជាព្រះបិតាឲ្យត្រេកអរយ៉ាងដូច្នេះឯង នាងជាអ្នកមានវត្តល្អ បានប្រាប់ផ្លូវសុគតិដល់ព្រះបិតា ដូចជាគេប្រាប់ផ្លូវដល់មនុស្សវង្វេង។

គ្រានោះ នារទព្រហ្ម ប្រមើលមើលជម្ពូទ្វីប បានឃើញព្រះបាទអង្គតិ

មានទិដ្ឋិវិបល្លាស ក៏ចុះមកអំពីព្រហ្មលោកដោយតំណែងខ្លួនជាឥសី មកឋិត នៅឰដ៏អាកាសក្នុងប្រាសាទខាងមុខនៃព្រះបាទវិទេហៈ។ នាងរុចា បានឃើញ នារទព្រហ្មនោះដែលមកដល់ហើយដ៏ថ្វាយបង្គំដោយសេចក្តីគោរព, ចំណែក ខាងព្រះរាជាបានឃើញនារទព្រហ្មនោះក៏ត្រឡប់ជាមានព្រះហឫទ័យតក់ស្លុត ខ្លាច ហើយចុះអំពីអសនៈសាកសួរនារទព្រហ្មថា លោកមានវណ្ណៈដូចជាទេវតា ញុំាងទិសទាំងអស់ឲ្យភ្លឺដូចព្រះចន្ទ តើលោកទើបនឹងមកពីណា, លោកចូរ ប្រាប់នាមនិងគោត្រឲ្យយើងបានស្គាល់ផង។ នារទព្រហ្ម –អាត្មាភាពទើបនឹង មកអំពីទេវលោក, មនុស្សទាំងឡាយតែងស្គាល់ថា អាត្មាភាពឈ្មោះ នារទៈ ជា កស្សបគោត្រ។ ព្រះរាជា –ទ្រង់ទ្រាយរបស់លោកក្តី ដំហរនិងដំណើររបស់ លោកក្តី ឰដ៏អាកាស មានសភាពជាអស្ចារ្យ, បពិត្រព្រះនារទៈ ខ្ញុំសួរសេចក្តី នេះនឹងលោក តើឫទ្ធិរបស់លោកនេះ កើតមានឡើងដោយហេតុអ្វី? នារទ-ព្រហ្ម –សច្ចៈ១ ធម៌១ ទមៈ១ ចាគៈ១ គុណធម៌ទាំងនេះ អាត្មាភាពបានប្រព្រឹត្ត មកហើយអំពីជាតិមុន ទើបអាត្មាភាពមានសន្ទុះចិត្តទៅតាមប្រាថ្នាបាន ព្រោះ ធម៌ដែលអាត្មាភាពបានសន្សំល្អហើយទាំងនោះឯង។ ព្រះរាជា –លោកបាន ប្រាប់ការសម្រេចនៃបុណ្យជារបស់អស្ចារ្យហើយ, បពិត្រនារទៈ ប្រសិនបើដូច ជាពាក្យដែលលោកពោលយ៉ាងនេះមែន ខ្ញុំសូមសួរសេចក្តីនេះនឹងលោកទៀត បើខ្ញុំសួរហើយ សូមលោកឆ្លើយដោយប្រពៃចុះ។ នារទព្រហ្ម –បពិត្រមហា រាជ ព្រះអង្គមានសេចក្តីសង្ស័យត្រង់ណា សូមទ្រង់សួរអាត្មាភាពចុះ អាត្មា ភាពដែលមកនេះជាប្រយោជន៍របស់ព្រះអង្គហើយ អាត្មាភាពនឹងញុំាងព្រះ

អង្គឲ្យដល់នូវភាពជាអ្នកមិនមានសេចក្តីសង្ស័យ ដោយន័យនិងដោយញាណទាំងឡាយ។ ព្រះរាជា –បពិត្រនារទៈ ខ្ញុំសូមសួរសេចក្តីនេះនឹងលោកថា ទេវតាមានមែនឬ? មាតាបិតាមានមែនឬ? បរលោកមានមែនឬ?។ នារទព្រហ្ម –ទេវតាមាន, មាតាបិតាមាន, បរលោកមាន តែពួកជនណាជាអ្នកជាប់នៅក្នុងកាម ជាអ្នកវង្វេងប្រកបដោយមោហៈ ពួកជននោះ រមែងមិនដឹងនូវបរលោក ឬមិនជឿថាបរលោកមានឡើយ។ ព្រះរាជា –បពិត្រនារទៈ បើលោកជឿថាលំនៅនៃជនទាំងឡាយដែលស្លាប់ទៅហើយ មានក្នុងបរលោកមែន, លោកចូរឲ្យកហាបណៈ៥០០ដល់ខ្ញុំក្នុងលោកនេះចុះ ខ្ញុំនឹងសងកហាបណៈជាមួយពាន់ដល់លោក ក្នុងបរលោកវិញ។ នារទព្រហ្ម –បើអាត្មាភាពដឹងថា មហារាជជាអ្នកមានសីល ជាអ្នកមានទាន សង្គ្រោះដល់ពួកស្មូម អាត្មាភាពនឹងឲ្យកហាបណៈ៥០០ ដល់មហារាជ ប៉ុន្តែបើមហារាជជាមនុស្សអាក្រក់ធ្លាក់ទៅរងទុក្ខក្នុងនរក តើអ្នកណានឹងទៅទារកហាបណៈមួយពាន់ក្នុងបរលោកបាន, សូម្បីក្នុងលោកនេះ បុគ្គលណាមិនមានធម៌ជាប្រក្រតី មានមារយាទដ៏លាមក ជាអ្នកខ្ជិលច្រអូស មានការងារអាក្រក់ បណ្ឌិតទាំងឡាយ ក៏មិនឲ្យបុគ្គលនោះ បុលឬខ្ចីទ្រព្យទេ ព្រោះថាការបានទ្រព្យអំពីបុគ្គលមានសភាពដូច្នោះមិនមានសោះឡើយ។ បពិត្រព្រះរាជា បើព្រះអង្គច្យុតចាកអត្តភាពនេះទៅ នឹងទតឃើញខ្លួនព្រះអង្គឯងកំពុងនៅក្នុងឋាននរក ដែលត្រូវហ្វូងក្អែក ត្មាតនិងក្ងោក ចឹកជញ្ជែងទំពាស៊ី មានខ្លួនធ្លុះធ្លាយ កំពុងមានឈាមហូរសស្រាក់ រងទុក្ខវេទនា តើអ្នកណានឹងទៅទារកកហាបណៈមួយពាន់ក្នុងបរលោកបាន។ សភាពងងឹត

ខ្លាំង រមែងមានក្នុងនរកនោះ ព្រះចន្ទនិងព្រះអាទិត្យក៏មិនមានក្នុងនរកនោះ មានផ្ទាំងងងឹតដ៏ក្រាសសព្វកាល មានសភាពគួរខ្លាច យប់ក៏មិនប្រាកដ ថ្ងៃក៏មិនប្រាកដ តើនរណាជាអ្នកត្រូវការដោយទ្រព្យ ហើយត្រាច់នៅក្នុងនរកដូច្នោះបាន។ ឆ្កែពពាលនិងឆ្កែលឿងទាំងពីរពួក មានកាយដ៏ធាត់ធំ មានកម្លាំងតែងខាំស៊ីនូវសត្វប្រព្រឹត្តអំពើអាក្រក់ ហើយច្យុតអំពីលោកនេះធ្លាក់ចុះទៅក្នុងបរលោក ដោយធ្មេញជាវិការៈនៃដែក, ព្រះអង្គកាលនៅក្នុងនរកកំពុងរងទុក្ខដ៏ខ្លាំងខ្លា ត្រូវឆ្កែដ៏កាចអាក្រក់ទាំងនោះខាំស៊ី មានខ្លួនធ្លុះធ្លាយ ហូរឈាមសស្រាក់ តើនរណានឹងទៅទារកហាបណៈមួយពាន់ អំពីព្រះអង្គក្នុងបរលោកបាន។ ពួកនាយនិរយបាលឈ្មោះកាលូបកាលៈ ក្នុងនរកនោះគួរឲ្យខ្លាចដ៏ពន្លឹក ជាបច្ចាមិត្រតែងចាក់កាប់សម្លាប់នរជនដែលធ្វើអំពើអាក្រក់ក្នុងកាលមុន ដោយព្រួញនិងលំពែងដែលសំលៀងមុតហើយ, ព្រះអង្គកាលនៅក្នុងនរក ត្រូវពួកនិរយបាលទាំងនោះ ចាក់ត្រង់ក្លៀក ត្រង់ឆ្អឹងជំនីរ វះពោះ មានខ្លួនធ្លុះធ្លាយ មានឈាមហូរចេញសស្រាក់ តើនរណានឹងទៅទារយកកហាបណៈមួយពាន់អំពីព្រះអង្គក្នុងបរលោកបាន។ ក្នុងនរកនោះ មានភ្លៀងបង្អុរចុះជាអាវុធផ្សេងៗ គឺលំពែង ព្រួញនិងច្បូក, ភ្លៀងអាវុធនោះ មានអណ្តាតឆេះដូចជារងើកភ្លើង រមែងធ្លាក់ចុះលើក្បាលនៃសត្វដែលធ្វើអំពើអាក្រក់, ក្នុងនរកនោះ មានខ្យល់ដ៏ក្តៅខ្លាចផ្សា, អត់ធន់បានដោយក្រ ព្រះអង្គដែលមានកម្មអាក្រក់ រមែងក្តៅក្រហាយអន្ទះសាជានិច្ច ស្ទុះឆ្លេឆ្លាទៅមកគ្មានពេលស្រាកស្រាន្តសោះ តើនរណានឹងទៅរកកហាបណៈមួយពាន់អំពីព្រះអង្គ

ក្នុងបរលោកបាន។ នាយនិរយបាល ទឹមព្រះអង្គក្នុងរថហើយចាក់ដោយជន្លួញ ព្រះអង្គស្ទុះទៅមក ជាន់ផែនដីមានអណ្តាតភ្លើងសន្ធោសន្ធៅទទួលរងទុក្ខវេទនាជានិច្ច តើនរណានឹងទារកហាបណៈមួយពាន់អំពីព្រះអង្គក្នុងបរលោកបាន។ ព្រះអង្គឡើងកាន់ភ្នំដ៏ដេរដាសដោយកាំបិត ជាភ្នំមានអណ្តាតភ្លើងប្រាលរន្ទាលឆ្អិនឆ្អៅ គួរឲ្យតក់ស្លុតក្រៃលែង ព្រះអង្គមានខ្លួនដាច់ធ្លុះធ្លាយកំពុងហូរឈាមសស្រាក់ ជាសត្វកំព្រាទួញយំខ្សែ្តងៗ តើនរណានឹងទារយកកហាបណៈមួយពាន់អំពីព្រះអង្គក្នុងបរលោកបាន។ ដើមឈើដ៏ខ្ពស់ស្មើនឹងពពកជាឈើច្រូងច្រាងដោយបន្លាជាវិការៈនៃដែកដ៏មុត ពួកស្ត្រីនិងបុរសដែលក្បត់ក្តី ក្បត់ប្រពន្ធ ត្រូវពួកនាយនិរយបាលកាន់ដាវ ជាអ្នកធ្វើតាមបញ្ជារបស់យមរាជកាប់ចាក់បង្ខំឲ្យឡើងដើមឈើនោះ។ ព្រះអង្គនឹងឡើងដើមរកាដែកក្នុងនរក មានកាយមុតដាច់រាត់រាយដោយឈាម មានស្បែករបករបោចក្តៅក្រហាយជានិច្ច មានទុក្ខវេទនាដ៏ខ្លាំងក្លានៅលើចុងដើមរកា តើនរណានឹងទារយកទ្រព្យនោះអំពីព្រះអង្គបាន។ ព្រះអង្គចេញអំពីនរកដើមរកានោះហើយក៏ធ្លាក់ទៅក្នុងស្ទឹងនរកឈ្មោះវេត្តរណី មានទឹកផ្សាក្តៅដ៏ដេរដាសដោយស្លឹកឈូកជាវិការៈនៃដែក រមែងហូរទៅតាមស្លឹកដ៏មុត។ ព្រះអង្គមានរាងកាយធ្លុះធ្លាយប្រឡាក់ដោយឈាម ដែលខ្សែទឹកហូរក្តួចទៅក្នុងស្ទឹងនរកឈ្មោះវេត្តរណីនោះ ជាស្ទឹងមិនមានអ្វីតោង តើនរណានឹងទៅទារកហាបណៈមួយពាន់អំពីព្រះអង្គក្នុងបរលោកបាន។

ព្រះរាជា –ខ្ញុំញាប់ញ័រ ដូចដើមឈើដែលបម្រុងនឹងបាក់, ខ្ញុំវង្វេង

សញ្ញាមិនដឹងទិស ក្តៅក្រហាយរឿយៗ ព្រោះភ័យនឹងបាបដែលខ្លួនបានធ្វើហើយ, បពិត្រឥសី ភ័យដ៏ធំកើតឡើងដល់ខ្ញុំ ព្រោះខ្ញុំបានស្តាប់ភាសិតដែលលោកសម្តែងហើយ។ បពិត្រឥសី សូមលោកជាទីពឹងរបស់ខ្ញុំ ដូចជាបុគ្គលដែលចុះទៅកាន់ទីពាក់កណ្តាលទឹក ព្រោះកាយត្រូវភ្លើងកំពុងឆេះឬដូចជាកោះរបស់ពួកជនដែលធ្លាយសំពៅក្នុងមហាសមុទ្រឬក៏ដូចជាប្រទីបរបស់ពួកជនដែលដើរទៅក្នុងទីងងឹត។ បពិត្រឥសី សូមលោកប្រៀនប្រដៅនូវអត្ថនិងធម៌ដល់ខ្ញុំផង កំហុសដ៏ធំ គឺខ្ញុំបានប្រព្រឹត្តកន្លងអស់កាលដ៏យូរហើយ, បពិត្រនារទៈ សូមលោកប្រាប់ផ្លូវនៃសេចក្តីបរិសុទ្ធិដល់ខ្ញុំ កុំឲ្យខ្ញុំធ្លាក់ទៅនរកឡើយ។

នារទព្រហ្ម –ព្រះបាទធតរដ្ឋ១ វេស្សមិត្ត១ អដ្ឋកៈ១ យមទត្តិ១ ឧសិន្នរៈ១ ព្រះរាជាទាំង៦អង្គនេះនិងពួកព្រះរាជាដទៃទៀត បានវៀរបង់នូវអធម៌ចេញ ហើយប្រព្រឹត្តកាន់នូវធម៌ ជាអ្នកបម្រើនៃពួកសមណព្រាហ្មណ៍ហើយបានទៅកាន់ឋានសួគ៌ យ៉ាងណា, បពិត្រព្រះអង្គជាធំលើផែនដី ព្រះអង្គចូរវៀរអធម៌ហើយប្រព្រឹត្តធម៌ យ៉ាងនោះចុះ។ មួយយ៉ាងទៀត សូមព្រះអង្គទ្រង់បញ្ជាពួករាជបុរសដែលនៅក្នុងបុរីរបស់ព្រះអង្គ ឲ្យឃោសនាថា នរណាឃ្លាននរណាស្រេក នរណាចង់បានកម្រងផ្កា នរណាចង់បានគ្រឿងលាប នរណាអាក្រាតចង់ស្លៀកដណ្តប់សំពត់ពណ៌ផ្សេងៗ នរណាចង់បានឆត្របាំងដើរក្នុងផ្លូវ នរណាចង់បានស្បែកជើងល្អ, ពួករាជបុរសចូរឃោសនាក្នុងបុរីរបស់ព្រះអង្គរាល់ព្រឹក រាល់ល្ងាចដូច្នេះឯង។ សូមព្រះអង្គកុំទឹមគោនិងសេះជាសត្វចិញ្ចឹមចាស់ៗ ដូចក្នុងកាលពីមុនទៀតឡើយ សត្វណាដែលមានកម្លាំងធ្វើ

ឧបការៈច្រើនដល់ព្រះអង្គៗ ចូរប្រទានការរក្សា ប្រទានអភ័យដល់សត្វទាំងនោះផង។

មួយយ៉ាងវិញទៀត កាយរបស់ព្រះអង្គៗ ចូរសម្គាល់ថាដូចរថ មានចិត្តជានាយសារថី មានការមិនបៀតបៀនជាភ្លៅ មានការចែករំលែកទានជាផ្ទុំ មានការសង្រួមជើងជាខ្នងកង់ មានការសង្រួមដៃជាគ្រពង មានការសង្រួមផ្ទៃជាប្រេងលាប មានការសង្រួមវាចាជាសូរដែលមិនលាន់ឮ មានពាក្យពិតជាតួនៃរថ មានការមិនញុះញង់ជាដំណាប់ជិតល្អមានវាចាពីរោះមិនមានទោសជាអង្គនៃរថ មានការពោលល្មមប្រមាណជាគ្រឿងចង មានសទ្ធានិងអលោភៈជាគ្រឿងប្រដាប់រថ មានការបន្ទន់បន្ទាបនិងអញ្ជលិកម្មជាទូក មានការមិនរឹងត្អឹងជាចន្ទោលរថ មានការសង្រួមសីលជាព្រ័ត្រជ្រាម មានការមិនក្រោធជាការមិនសណ្តកឬមិនរង្គោះរង្គើ មានសុចរិតធម៌ជាឆត្រស មានពាហុសច្ចៈជាខ្សែចន្ទោល មានចិត្តតាំងនៅនឹងជាអាសនៈ មានការដឹងនូវកាលជាខ្លឹមដ៏វិចិត្រ មានសេចក្តីក្លៀវក្លាជាចន្ទល់ មានការប្រព្រឹត្តិបន្ទន់ខ្លួនជាខ្សែ មានការមិនមើលងាយជានឹមដ៏ស្រាល មានចិត្តមិនរួញរាជាកម្រាល មានការអប់រំធ្វើឲ្យចម្រើនដោយបញ្ញាជាអំបោស សតិរបស់ព្រះអង្គទុកជាជន្លួញ មានព្យាយាមដ៏មាំជាខ្សែបរ។ ចិត្តដែលទូន្មានបានហើយរមែងទៅកាន់ផ្លូវល្អ ដូចរថដែលទៅកាន់ផ្លូវត្រង់ ដោយសារសេះទាំងឡាយដែលនាយសារថីហ្វឹកហ្វឺនល្អហើយ ព្រោះសេចក្តីប្រាថ្នានិងសេចក្តីលោភជាផ្លូវខុស ការសង្រួមជាផ្លូវត្រង់ល្អ។ បពិត្រព្រះរាជា កាលបើរថគឺកាយរបស់ព្រះអង្គ ស្ទុះទៅក្នុងរូប សំឡេង ក្លិន

រស តួបញ្ញាជាជនួញសម្រាប់គោះ ឯខ្លួនព្រះអង្គជានាយសារថី ក្នុងរថនោះ។ បពិត្រព្រះរាជា បើការប្រព្រឹត្តស្មើនិងសេចក្តីព្យាយាមដ៏មាំដោយយាន គឺកាយនោះហើយ រមែងសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាង សត្វរមែងមិនទៅកាន់នរកឡើយ។

នារទព្រហ្ម បានសម្តែងធម៌ទូន្មានព្រះរាជាព្រះនាមអង្គតិ ឲ្យលះបង់ទិដ្ឋិអាក្រក់ដែលយល់ខុស មិនជឿកម្មនិងផលរបស់កម្ម ហើយឲ្យកាន់យកនូវសម្មាទិដ្ឋិឡើងវិញ ព្រោះហេតុនោះ អ្នកទាំងឡាយចូរចាំនូវនិទាននេះថា អលាតសេនាបតី គឺទេវទត្ត, សុនាមៈអាមាត្យ គឺភទ្ទជិ, វិជយៈអាមាត្យ គឺសារីបុត្ត, ទាសៈឈ្មោះវីជកៈ គឺមោគ្គល្លាន, អចេលក៍ឈ្មោះគុណៈ គឺសុនក្ខត្តលិច្ឆវីបុត្ត, នាងរុចា បានញ៉ាំងព្រះរាជា ជាព្រះបិតាឲ្យជ្រះថ្លា គឺអានន្ទ, ព្រះរាជា (អង្គតិ) ដែលមានទិដ្ឋិអាក្រក់ ក្នុងកាលនោះ គឺឧរុវេលកស្សប, នារទព្រហ្ម គឺ ពោធិសត្វ ។

ស្រាវជ្រាវដោយៈ ថាច់ សុតឹម